ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ២១/១១-សាន់ ស្កាយ**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជកៈ **ម៉ារ សំបូរណា**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិតៈ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើៈ **គង់ ផល្លះ**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន សាន់ ស្កាយ (ខេមបូឌា) អ៊ិនដាស្ទ្រី**

អាសយដ្ឋាន : ភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១៦ ៧៤៤ ៧២៣ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោក លោក ជ័យ សុវ័ត្ថ | ប្រធានរដ្ឋបាល |
| ២- លោក ជួន នីម | ជំនួយការផ្នែកធនធានមនុស្ស |
| ៣- កញ្ញា ចិន ពៅ | កម្មករក្រុមដេរ ២ |
| ៤- កញ្ញា សើ លាភ | កម្មករ QC |
| ៥- កញ្ញា ទ្រី ថារី | កម្មករដេរ |
| ៦- កញ្ញា សុខ សុផល | ពេទ្យ |
| ៧- កញ្ញា ខៀវ ណារ៉ែន | កម្មករដេរ |

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥.២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

| | |
|---|---|
| ៨- លោក យស់ ចាន់រី | ជាងម៉ាស៊ីន |
| ៩- លោក ជួន ភីន | ជាងម៉ាស៊ីន |
| ១០- លោក ខ្វាន់ វុដ្ឋា | កម្មករកាត់ុង |
| ១១- កញ្ញា ឡុង រតនា | កម្មករពិនិត្យ |

២- **ភាគីកម្មករនិយោជិត**

ឈ្មោះ : **សម្ព័ន្ធសហជីពចលនាកម្មករ**

អាសយដ្ឋាន : ភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៤៨២ ២៨៤ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត: **អវត្តមាន**

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សូមឱ្យក្រុមហ៊ុនទទួលស្គាល់សហជីពចលនាកម្មករប្រចាំក្រុមហ៊ុនកាត់ដេរ សាន់ស្តាយ ។

២- ក្រុមហ៊ុនត្រូវធ្វើការណែនាំដល់ប្រធានក្រុម និងប្រធានផ្នែកឱ្យប្រើពាក្យសំដីសមរម្យមកលើកម្មករ ។

៣- ថែមម៉ោងស្ថិតលើគោលការណ៍ស្ម័គ្រចិត្ត ។

៤- បញ្ឈប់ការដាក់កំណត់ឱ្យកម្មករដេរហួសកំលាំង ។

៥- សូមឱ្យក្រុមហ៊ុនផ្តល់លុយលើកទឹកចិត្តដល់កម្មករនិយោជិតឡើងវិញ ។

៦- សូមឱ្យក្រុមហ៊ុនបន្ថែមលុយបាយចំនួន ១៥០០ រៀល ទៀត ចំពោះការធ្វើការថែមម៉ោងពីម៉ោង ៤ម៉០០ ដល់ម៉ោង ៧ម៉៣០ នាទី ។

៧- ក្រុមហ៊ុនត្រូវផ្តល់ភាពងាយស្រួលដល់កម្មករនិយោជិតក្នុងការសុំច្បាប់ ។

៨- ចំពោះធ្វើការថ្ងៃសៅរ៍សុំចេញម៉ោងបួន ។

៩- ក្រុមហ៊ុនត្រូវធ្វើទារកដ្ឋានសម្រាប់ដាក់ក្មេង ។

១០- ក្រុមហ៊ុនត្រូវផ្តល់ពេលវេលាមួយម៉ោងសម្រាប់កម្មការិនីទៅបំបៅដោះកូន ។

១១- ក្រុមហ៊ុនត្រូវលប់បំបាត់ចោលចំពោះការប្រើកាតចូលបន្ទប់ទឹក ។

១២- យើងខ្ញុំទាំងអស់គ្នាសូមធ្វើការបដិសេធទាំងស្រុងចំពោះស្នាមមេដៃដែលក្រុមហ៊ុនបង្ខំឱ្យយើងផ្តិតកន្លងមក ។

១៣- សូមឱ្យក្រុមហ៊ុនសាងសង់បន្ទប់ទឹកបន្ថែមទៀត ។

១៤- សូមឱ្យក្រុមហ៊ុនសាងសង់រោងបាយសម្រាប់កម្មករនិយោជិតហូបបាយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)( មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ ( អាណត្តិទី៨ ) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ ( ក ) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ១៦៣ កប/អក/វក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ ( ទល់មុខវិទ្យាល័យឥន្ទ្រទេវី ), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ( វេលាម៉ោង ០៨ : ៣០ នាទី ព្រឹក ) ។

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារ បានទទួលបណ្តឹងរបស់សម្ព័ន្ធសហជីពចលនាកម្មករ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអនូវលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីធ្វើការផ្សះផ្សាវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ១៤ ចំណុច លើការទាមទារចំនួន ១៤ ចំណុច ។ ចំណុចមិនសះជាចំនួន ១៤ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន សាន់ ស្តាយ លេខ ១៦៣ កប/អក/ វក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និង សម្ព័ន្ធសហជីពចលនាកម្មករ មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១៤ ចំណុចនេះ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ វេលាម៉ោង ០៨:៣០ នាទី ព្រឹក ប៉ុន្តែ សម្ព័ន្ធសហជីពចលនាកម្មករ មិនបានមកចូលរួមសវនាការ ឬមិនបានស្នើសុំពន្យាពេលសវនាការ ឬបញ្ជាក់ពីមូលហេតុត្រឹមត្រូវណាមួយដែលមិនបានមកចូលរួមសវនាការអាជ្ញាកណ្តាលដែរ គ្រាន់តែបញ្ជាក់ថា ពួកគេមិនមកចូលរួមសវនាការទេ ទោះបីជា

6

មុនថ្ងៃសវនាការ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទំនាក់ទំនងពួកគេតាមទូរស័ព្ទបន្ថែមទៀត ក៏ដោយ ។ ចំណែកឯ ភាគីនិយោជកវិញ បានមកចូលរួមសវនាការតាមការកោះហៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងធ្វើការពិចារណា និងសម្រេចលើចំណុចវិវាទក្នុងសំណុំរឿងនេះ ដូចខាងក្រោម :

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន សាន់ ស្កាយ ជូនលោក ជ័យ សុវ័ត្ថ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០១១ ។

២- អនុសញ្ញារួមរវាងសហជីពទ្រទ្រង់កម្មករ និងអ្នកគ្រប់គ្រងក្រុមហ៊ុន សាន់ ស្កាយ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៨ ។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន សាន់ ស្កាយ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៥ ។

៤- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន សាន់ ស្កាយ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៥ ។

៥- លក្ខន្តិកៈក្រុមហ៊ុន សាន់ ស្កាយ ចុះថ្ងៃទី១៤ ខែកុមៈ ឆ្នាំ២០០៥ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន សាន់ ស្កាយ លេខ ១៦៣ កប/អក/វក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន សាន់ ស្កាយ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ ២០១១ ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១១៨ កប/អក/វក/លកអ. ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១១៩ កប/អក/វក/លកអ. ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ ។

6

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១៤២ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១៤៣ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១។

**អន្តរហេតុ : គ្មាន**

## ហេតុផលនៃសេចក្តីសម្រេច

នៅក្នុងសំណុំរឿងនេះ សម្ព័ន្ធសហជីពចលនាកម្មករដែលជាដើមបណ្តឹង មិនបានមកចូលរួមសវនាការ មិនបានស្នើសុំពន្យាពេលសវនាការ ឬបញ្ជាក់ពីមូលហេតុត្រឹមត្រូវណាមួយ ដែលមិនបានមកចូលរួមសវនាការអាជ្ញាកណ្តាលដែរ គ្រាន់តែ បញ្ជាក់ថា ពួកគេមិនមកចូលរួមសវនាការទេ ទោះបីជាមុនថ្ងៃសវនាការ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទំនាក់ទំនងពួកគេតាមទូរស័ព្ទបន្ថែមទៀតក៏ដោយ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើសំណុំរឿងនេះ ដូចខាងក្រោម:

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រការ ២១ ចែងថា *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់ "*។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាល ត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន "*។

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសគី, លេខ ២៧/០៧-អ៊ឹម និង វ៉ៃ ៣, លេខ ១៣៨/០៨-ម៉ាលីន និងលេខ ១១/១១-ជូន តិចថាយល៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយប្រការ ២១ ខាងលើនេះថា មានលក្ខខណ្ឌបីដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងបាន ***"លក្ខខណ្ឌទី១ : ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ លក្ខខណ្ឌទី២ : ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងលក្ខខណ្ឌទី៣ : ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន "*** ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាល ក្នុងសំណុំរឿងមុនៗខាងលើដែរ។ ហេតុនេះហើយ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ?

**លក្ខខណ្ឌទី១ : ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ**

មន្ត្រីលេខាធិការដ្ឋានបានទំនាក់ទំនងទៅកាន់ភាគីកម្មករនិយោជិត ជូនដំណឹងពីសវនាការអាជ្ញាកណ្តាល ប៉ុន្តែ សម្ព័ន្ធសហជីពចលនាកម្មករដែលជាដើមបណ្តឹងបានបញ្ជាក់ថា មិនមកចូលរួមសវនាការទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីសម្ព័ន្ធសហជីពចលនាកម្មករពិតជាទទួលបានការអញ្ជើញត្រឹមត្រូវពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ឱ្យចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិតប្រាកដមែន។ **ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។**

**លក្ខខណ្ឌទី២ : ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "*ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល*" នៅក្នុងប្រការ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់។

ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា:

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

ក្នុងករណីនេះ សម្ព័ន្ធសហជីពចលនាកម្មករ មិនបានចូលរួមគ្រប់ដំណាក់កាលទាំងបួនខាងលើនេះ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីសហជីព និងកម្មករនិយោជិត មិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល តាមខ្លឹមសារនៃលក្ខខណ្ឌទី២ នៃប្រការ២១ ខាងលើនេះទេ។ **ហេតុនេះហើយ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។**

**លក្ខខណ្ឌទី៣ : ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

នៅក្នុងករណីនេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទំនាក់ទំនងតាមទូរស័ព្ទរំលឹកទៅភាគីនិយោជក និង សម្ព័ន្ធសហជីពចលនាកម្មករ អំពីសវនាការអាជ្ញាកណ្តាល ប៉ុន្តែ សម្ព័ន្ធសហជីពចលនាកម្មករ បានឆ្លើយថា មិនមានកម្មករនិយោជិតធ្វើការទាមទារទៀតទេ ដូចនេះ ពួកគាត់មិនមកចូលរួមសវនាការ ដើម្បីធ្វើការ

6

ទាមទារទៀតទេ។ ចំណែកភាគី ក្រុមហ៊ុនបានអញ្ជើញមកចូលរួមក្នុងសវនាការតាមកាលកំណត់។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីសម្ព័ន្ធសហជីពចលនាកម្មករ **មិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះទេ។ ហេតុនេះហើយ លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ។**

ដូច្នេះ ជាសរុបសេចក្តីមក លក្ខខណ្ឌទាំងបី ដែលមានចែងក្នុងប្រកាស ២១ ខាងលើ ត្រូវបានបំពេញ។

ផ្អែកតាមវិធាន និងប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ទោះបីសម្ព័ន្ធសហជីពចលនាកម្មករដែលជាដើមបណ្តឹងមិនចូលរួមក្នុងដំណើរការអាជ្ញាកណ្តាល ក៏ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចក្នុងការចេញសេចក្តីបង្គាប់ដែរ។

បន្ថែមពីលើនេះទៀត នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្តល់ឱកាសគ្រប់គ្រាន់ដល់សម្ព័ន្ធសហជីពចលនាកម្មករដែលជាភាគីដើមបណ្តឹងក្នុងការធ្វើការការពារចំពោះការទាមទាររបស់កម្មករនិយោជិតដែលពឹងពាក់ខ្លួនតាមនីតិវិធីច្បាប់ស្តីពីការងារ។ ប៉ុន្តែ ភាគីសហជីពបានជ្រើសរើសការមិនចូលរួមសវនាការ និងបោះបង់ឱកាសក្នុងការបង្ហាញភស្តុតាង ដើម្បីគាំទ្រការទាមទាររបស់ខ្លួនទៅវិញ។ ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់ហេតុផល និងភស្តុតាងនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងរបស់ខ្លួន។ ប៉ុន្តែ ក្នុងសំណុំរឿងនេះ សម្ព័ន្ធសហជីពចលនាកម្មករដែលជាភាគីដើមបណ្តឹងមិនបានផ្តល់នូវហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា សម្ព័ន្ធសហជីពចលនាកម្មករបានបោះបង់ចោលបណ្តឹងរបស់ខ្លួន។ សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងលេខ ២១/១១-សាន់ ស្កាយ នេះ។

យោងតាមហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅ ៖

## សម្រេច និង បង្គាប់

សម្រេចបិទសំណុំរឿងលេខ ២១/១១-សាន់ ស្កាយ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **ម៉ារ សំបូរណា**

ហត្ថលេខា៖ -----------------------------------

THE ARBITRATION COUNCIL

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **អន ណាន**

ហត្ថលេខា: ---------------------------------

**ប្រធានក្រុមអាជ្ញាកណ្ដាល :**

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ---------------------------------